COUNT US IN 2020

There's Power In Being Counted

ASIAN AMERICANS ADVANCING JUSTICE

COUNTUSIN2020.ORG

# ជម្រើសបំពេញតាមអ៊ិនធឺណិតក្នុងជំរឿនឆ្នាំ 2020

*មានសំណួរមែនទេ? សូមហៅទូរស័ព្ទទៅកាន់ខ្សែទូរស័ព្ទទាន់ហេតុការណ៍ផ្នែកជំរឿនរបស់យើង តាមលេខ 844-2020-API សម្រាប់ជំនួយគាំទ្រជាភាសាអង់គ្លេស និងភាសាដទៃផ្សេងទៀត។ សូមចូលមើលគេហទំព័រ www.CountUsIn2020.org/hotline សម្រាប់ព័ត៌មានបន្ថែម។*

ជំរឿនឆ្នាំ 2020 នឹងរាប់មនុស្សគ្រប់រូបដែលរស់នៅក្នុងសហរដ្ឋអាមេរិក។ ជំរឿននេះធ្វើឡើងជារៀងរាល់ 10 ឆ្នាំម្តង ហើយប្រាប់ពីរបៀបដែលថវិកាសហព័ន្ធចំនួន 1.5 ទ្រីលានដុល្លារត្រូវបានបែងចែកជារៀងរាល់ឆ្នាំ។ មានវិធីពីរបីយ៉ាងដែលជំរឿនឆ្នាំ 2020 នឹងខុសគ្នាពីជំរឿនឆ្នាំ 2010។

## លោកអ្នកអាចបំពេញជំរឿនឆ្នាំ 2020 តាមអនឡាញ!

ជំរឿនឆ្នាំ 2020 នឹងជាជំរឿនលើកដំបូងដែលនឹងអនុញ្ញាតឱ្យមនុស្សគ្រប់រូបបំពេញបែបបទជំរឿនតាមអនឡាញ។ លោកអ្នកនឹងទទួលបានការអញ្ជើញមួយដើម្បីបំពេញនៅពាក់កណ្តាលខែមីនា។ ដោយអាស្រ័យលើរបៀបដែលតំបន់របស់លោកអ្នកទំនងជាបំពេញតាមអនឡាញ លោកអ្នកនឹងទទួលបានការអញ្ជើញមួយដែលលើកទឹកចិត្តលោកអ្នកឱ្យឆ្លើយតបតាមអនឡាញ ឬការអញ្ជើញមួយរួមជាមួយកម្រងសំណួរជាក្រដាស។

គ្រួសារភាគច្រើននឹងទទួលបានលិខិតមួយនៅក្នុងសំបុត្រប្រៃសណីយ៍ដែលអញ្ជើញពួកគេឱ្យបំពេញតាមអនឡាញ ដោយមានលេខសម្គាល់គ្រួសារពិសេសតែមួយគត់ និងអាសយដ្ឋានវិបនៃគេហទំព័រការិយាល័យជំរឿនផ្លូវការ។

- ត្រូវប្រាកដថា លោកអ្នកចូលទៅកាន់គេហទំព័រជំរឿនផ្លូវការឆ្នាំ 2020 ដើម្បីបំពេញ។
- លេខសម្គាល់នេះគួរតែត្រូវបានប្រើដើម្បីបំពេញទម្រង់បែបបទតាមអនឡាញមួយ ដែលលោកអ្នកគួររាយមនុស្សគ្រប់រូបដែលរស់នៅអាសយដ្ឋានរបស់លោកអ្នក។

លោកអ្នកនឹងអាចបំពេញទម្រង់បែបបទដោយប្រើកុំព្យូទ័រ ថេប្លេត ឬស្មាតហ្វូន។

- កម្មវិធីរុករកល្អបំផុតដែលត្រូវប្រើនៅពេលបំពេញតាមអនឡាញគឺ Internet Explorer, Safari, Chrome ឬ Firefox ។
- ឧបករណ៍ដ៏ល្អបំផុតសម្រាប់ការបំពេញតាមអនឡាញគឺ កុំព្យូទ័រ, iPhone ជំនាន់ទី 5 និងក្រោយៗទៀត ជំនាន់ iPad ភាគច្រើន និងទូរស័ព្ទ និងថេប្លេត Samsung Galaxy។

ប្រសិនបើលោកអ្នកមិនមានអ៊ិនធឺណិតទេ លោកអ្នកនៅតែអាចចូលរួមក្នុងជំរឿនឆ្នាំ 2020 បាន។

- ប្រសិនបើលោកអ្នកមិនបំពេញជំរឿនតាមអនឡាញទេ ការិយាល័យជំរឿននឹងផ្ញើទម្រង់បែបបទជាក្រដាសក្នុងសំបុត្រទៅលោកអ្នកក្នុងពេលផ្ញើសំបុត្រលើកទី4។ ការផ្ញើសំបុត្រលើកទី4 គឺជាផ្នែកមួយនៃដំណើរការរបស់ពួកគេសម្រាប់ការផ្ញើការណែនាំ និងការរំលឹកជូនលោកអ្នកដើម្បីបំពេញតាមជំរឿន។
- បណ្ណាល័យ និងអង្គភាពសហគមន៍មួយចំនួននឹងរៀបចំកុំព្យូទ័រ ឬថេប្លេតដែលយើងអាចបំពេញជំរឿនបាន។ នឹងមិនមានការកំណត់ចំពោះចំនួននៃការឆ្លើយតបដែលអាចត្រូវបានធ្វើឡើងពីឧបករណ៍តែមួយទេ។

## ការគាំទ្រផ្នែកភាសាសម្រាប់ភាសាដែលមិនមែនអង់គ្លេស ចំនួន 12 តាមអនឡាញ និងតាមទូរស័ព្ទ

*ទម្រង់បែបបទតាមអនឡាញ*អាចរកបានជាភាសាមិនមែនអង់គ្លេសចំនួន 12៖ អេស្ប៉ាញ ចិន (សាមញ្ញ) វៀតណាម កូរ៉េ រុស្ស៊ី អារ៉ាប់ តាហ្គាឡុក ប៉ូឡូញ បារាំង ក្រេអូលហៃទី ព័រទុយហ្គាល់ និងជប៉ុន។

លោកអ្នកក៏អាចហៅទូរស័ព្ទទៅកាន់ការិយាល័យដើម្បីបំពេញជំរឿនតាម*ទូរស័ព្ទ*ឬដើម្បីសួរសំណួរបានផងដែរ។ ការគាំទ្រតាមទូរស័ព្ទត្រូវបានផ្តល់ជូនជាភាសាមិនមែនអង់គ្លេសចំនួន 12 ភាសា៖ អេស្ប៉ាញ ចិន (កុកងឺ និងកន្តាំង) វៀតណាម កូរ៉េ រុស្ស៊ី អារ៉ាប់ តាហ្គាឡុក ប៉ូឡូញ បារាំង ក្រេអូលហៃទី ព័រទុយហ្គាល់ និងជប៉ុន។

*ទម្រង់បែបបទជាក្រដាស*គឺអាចរកបានតែជាភាសាអង់គ្លេស និងអេស្ប៉ាញប៉ុណ្ណោះ។

មគ្គុទេសក៍ភាសាដែលជាឧបករណ៍យោងត្រូវបានបកប្រែដែលប្រជាជនអាចប្រើដើម្បីជួយបំពេញទម្រង់បែបបទជាភាសាអង់គ្លេសរបស់ពួកគេ ហើយសទ្ទានុក្រមសម្រាប់ភាសាមិនមែនអង់គ្លេសចំនួន 59 អាចរកបាននៅលើគេហទំព័ររបស់ការិយាល័យជំរឿន នៅអាសយដ្ឋាន www.2020census.gov/en/languages.html។ សូមមើលសន្លឹកព័ត៌មានរបស់យើងតាម www.CountUsIn2020.org/resources សម្រាប់ព័ត៌មានបន្ថែមអំពីអ្វីដែលទម្រង់បែបបទជំរឿនសួរ របៀបឆ្លើយតប និងរបៀបទទួលបានជំនួយ។

## ការរក្សាចម្លើយតាមអនឡាញរបស់អ្នកឱ្យមានសុវត្ថិភាព

ការិយាល័យជំរឿនកំពុងធ្វើការដើម្បីរក្សាការឆ្លើយតបតាមអនឡាញរបស់លោកអ្នកឱ្យមានសុវត្ថិភាព។
ការិយាល័យជំរឿននឹងអ៊ិនគ្រីបទិន្នន័យរបស់លោកអ្នកទៅជាទម្រង់ដែលពិបាកយល់។
ការិយាល័យជំរឿននឹងអ៊ិនគ្រីបទិន្នន័យចម្លើយពីរដង។
ការអ៊ិនគ្រីបលើកដំបូងធ្វើឡើងនៅពេលលោកអ្នកចុចប៊ូតុងបញ្ជូន។
សំណុំនៃការអ៊ិនគ្រីបទីពីរធ្វើឡើងនៅពេលដែលចម្លើយឈានដល់មូលដ្ឋានទិន្នន័យរបស់ការិយាល័យជំរឿន។ ការិយាល័យជំរឿននឹងត្រួតពិនិត្យដើម្បីធ្វើឱ្យប្រាកដថា អ្នកកន្លែងបន្លំ
អ្នកលួចចូលតាមអ៊ីនធឺណិត ឬតួអង្គ
អាក្រក់ៗផ្សេងៗទៀតមិនអាចចូលដល់ចម្លើយនានាដែលបានដាក់តាមរយៈទម្រង់បែបបទលើអនឡាញបានឡើយ។

លើសពីនេះទៀត
ការិយាល័យជំរឿនមិនត្រូវបានអនុញ្ញាតឱ្យចែករំលែកព័ត៌មានបុគ្គលរបស់លោកអ្នកជាមួយទីភ្នាក់ងាររដ្ឋាភិបាល មន្ត្រីអន្តោប្រវេសន៍ ឬសាធារណៈជនឡើយ។
ច្បាប់ដ៏តឹងរឹងការពារចម្លើយរបស់លោកអ្នកពីការចែករំលែក!
ចម្លើយជំរឿនអាចត្រូវបានប្រើប្រាស់សម្រាប់តែគោលបំណងស្ថិតិប៉ុណ្ណោះ។

*អ្នកអាចស្វែងរកព័ត៌មានបន្ថែមទៀតអំពីជំរឿននៅ www.CountUsIn2020.org/resources*។

# ជម្រើសនៃការឆ្លើយតបតាមអ៊ីនធឺណិតនៅក្នុងជំរឿនឆ្នាំ 2020

**លោកអ្នកអាចឆ្លើយនឹងជំរឿនៈ**

- ☑ តាមអ៊ីនធឺណិត
- ☑ តាមទូរស័ព្ទ
- ☑ តាមទម្រង់បែបបទជាក្រដាស

ប្រសិនបើលោកអ្នកមិនបំពេញតាមអនឡាញ ឬតាមទូរស័ព្ទទេ ការិយាល័យជំរឿននឹងផ្ញើទម្រង់បែបបទជាក្រដាសជូនលោកអ្នក

ការិយាល័យជំរឿននឹងផ្ញើសេចក្តីជូនដំណឹងមួយដល់លោកអ្នកនៅក្នុងសំបុត្រជាមួយនឹងលេខសម្គាល់គ្រួសារ
និងតំណមួយទៅកាន់គេហទំព័រផ្លូវការជំរឿន

ចូលទៅកាន់គេហទំព័រផ្លូវការជំរឿន 2020 ដើម្បីបំពេញ

*ប្រសិនបើលោកអ្នកបាត់លេខសម្គាល់គ្រួសាររបស់លោកអ្នក លោកអ្នកនៅតែអាចបំពេញជំរឿនតាមអនឡាញបានដោយផ្តល់អាសយដ្ឋានរបស់លោកអ្នក។*

សេចក្តីជូនដំណឹងរបស់ការិយាល័យជំរឿននឹងមានលេខទូរស័ព្ទជំរឿនឆ្នាំ 2020

លោកអ្នកអាចទូរស័ព្ទទៅលេខទូរស័ព្ទនោះដើម្បីបំពេញជំរឿន

*ការគាំទ្រផ្នែកភាសាសម្រាប់ភាសាដែលមិនមែនអង់គ្លេសចំនួន 12 អាចរកបានតាមអនឡាញ និងតាមទូរស័ព្ទ*

**សូមប្រាកដថា**
**រាប់បញ្ចូលមនុស្សគ្រប់រូបដែលរស់នៅអាសយដ្ឋានរបស់លោកអ្នក**
**នៅពេលលោកអ្នកបំពេញទម្រង់បែបបទ**